# ព្រះរាជក្រម

នស/រកម/០៦០៦/០១៤

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានលទ្ធភាពពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះ បានទាន់ពេលវេលាស្របតាមមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាបាសែល ស្ដីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់ឆ្លងដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែលស្ដីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលធ្វើនៅទីក្រុងបាសែល ប្រទេសស្វីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦.០១៨ **ព្រះមហាក្សត្រ និងព្រះរាជបល្ល័ង្ក**

**នរោត្ដម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ: ៥២១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋាភិបាល

ឃុន ចិនកេន

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាបាសែល ស្ដីពីការត្រួតពិនិត្យចលនា ដឹកជញ្ជូន និងការបោះបង់ចោលសំណល់ គ្រោះថ្នាក់ឆ្លងដែន

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងអនុសញ្ញាបាសែលស្ដីពីការត្រួតពិនិត្យចលនាដឹកជញ្ជូន និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន ដែលធ្វើនៅទីក្រុងបាសែល ប្រទេសស្វីស នាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៨៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

នៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៦

នស/រកម.០៦០៦/០១៨ ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ហត្ថលេខា

ម៉ុក ម៉ារ៉េត

លេខ: ៤២១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ចិនកេន

# អត្ថបទ អនុសញ្ញាបាសែល
# ស្តីពី
# ការត្រួតពិនិត្យចលនាដឹកជញ្ជូន
# និងការបោះបង់ចោលសំណល់គ្រោះថ្នាក់ឆ្លងដែន

*Text of Basel Convention*
*on*
*the Control of Transboundary Movements*
*of Hazardous Wastes and Their disposal*

## មាត្រាទី ១
## វិសាលភាពរបស់អនុសញ្ញាអន្តរជាតិ " បាសែល "

១- គោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រធានបទនៃការដឹកជញ្ជូនសំណល់ឆ្លងដែន ដែលជាប្រភេទសំណល់គ្រោះថ្នាក់ ។

ក- ប្រភេទសំណល់ស្ថិតក្នុងឧបសម្ព័ន្ធទី I មិនត្រូវមានលក្ខណៈដូចសំណល់នៅក្នុងឧបសម្ព័ន្ធទី III ឡើយ ។

ខ- ប្រភេទសំណល់ដែលមិនស្ថិតក្នុងវាក្យខ័ណ្ឌ " ក " ប៉ុន្តែអាចកំណត់ ឬក៏អាចចាត់ទុកថាជាសំណល់គ្រោះថ្នាក់បាន ដោយយោងតាមច្បាប់នៃប្រទេសនិមួយៗរបស់ភាគី ដែលធ្វើការនាំចេញ នាំចូល និងធ្វើការដឹកជញ្ជូនឆ្លងកាត់ ។

២- "សំណល់ដទៃទៀត" ដែលជាគោលបំណងរបស់អនុសញ្ញា គឺសំដៅលើប្រភេទសំណល់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី II ។

៣- សំណល់ដែលមានជាតិវិទ្យុសកម្ម ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញាអន្តរជាតិ "បាសែល" ទេ ប៉ុន្តែវាជាភារកិច្ចត្រួតពិនិត្យរបស់ប្រព័ន្ធអង្គការអន្តរជាតិ ដែលមានច្បាប់អន្តរជាតិកំណត់ទៅលើសារធាតុវិទ្យុសកម្មដាច់ដោយឡែក ។

៤- ការបញ្ចេញសំណល់ពីការប្រើប្រាស់ធម្មតាតាមនាវា ពុំស្ថិតក្រោមការត្រួតពិនិត្យរបស់អនុសញ្ញានេះទេ ប៉ុន្តែវាស្ថិតក្រោមការត្រួតពិនិត្យរបស់ច្បាប់អន្តរជាតិផ្សេងៗទៀត ។

## មាត្រាទី ២
## និយមន័យ

១- "**សំណល់**" ជាសារធាតុ ឬវត្ថុទាំងឡាយណាដែលត្រូវបានបោះចោល ឬមានបំណងបោះចោល ឬត្រូវអោយបោះចោល ដោយអនុលោមតាមច្បាប់ជាតិរបស់ប្រទេសនិមួយៗ ។

២- "**ការគ្រប់គ្រង**" ជាការប្រមូល ការដឹកជញ្ជូន និងការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត រួមទាំងការថែរក្សាទីលានចាក់សំណល់បន្ទាប់ពីធ្វើការចាក់ចោលរួចមក ។

៣- "**ការដឹកជញ្ជូនឆ្លងដែន**" ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀតពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ដែលតំបន់នោះស្ថិតនៅក្រោមអំណាចត្រួតត្រារបស់ប្រទេសផ្សេងគ្នា យ៉ាងហោចណាស់ត្រូវពាក់ព័ន្ធនឹងច្បាប់ដឹកជញ្ជូននៃប្រទេសចំនួនពីរដែរ ។

៤- "**ការបោះបង់ចោល**" រាល់ដំណើការនៃការបោះបង់ចោលសំណល់ នឹងត្រូវបានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី IV នៃអនុសញ្ញាអន្តរជាតិ "បាសែល" នេះ ។

៥- "**ទីតាំងអនុញ្ញាត ឬមធ្យោបាយសំរាប់ទុកដាក់សំណល់**" គឺសំដៅលើទីកន្លែង ឬមធ្យោបាយសំរាប់ការចាក់ចោលសំណល់គ្រោះថ្នាក់ ឬសំណល់ដទៃទៀត ដែលត្រូវបានអនុញ្ញាតអោយដំណើរការសំរាប់